# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ** : ០០២/១៩-០៩-២០០៧-អវតក/អជសដ

**ដាក់ទៅ** : អង្គជំនុំជម្រះសាលាដំបូង

**ថ្ងៃដាក់** : ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦

**ភាគីអ្នកដាក់** : សហព្រះរាជអាជ្ញាអន្តរជាតិ

**ភាសាដើម** : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Mar-2016, 13:47
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សាធារណៈ** អមដោយ **ឧបសម្ព័ន្ធសម្ងាត់មិនផុត ១**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## ការដាក់បញ្ចូលរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារសំណុំរឿង០០៣ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន, ប្រធាន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

ចៅក្រម Claudia FENZ

ចៅក្រម យូរ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

លោក ពេជ អង្គ

លោកស្រី Marie GUIRAUD

**ចម្លងជូន:**

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**

លោក សុន អរុណ

លោក Victor KOPPE

លោក គង់ សំអុន

លោកស្រី Anta GUISSÉ

**មេធាវីប្រចាំការ:**

លោកស្រី ទូច វណ្ណល័ក្ស

លោក Calvin SAUNDERS

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

## I. ការដាក់បង្ហាញ

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("សហព្រះរាជអាជ្ញា") នៅទីនេះ សូមដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៤ និងរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងសំណុំរឿង០០៣ ដែលត្រូវគ្នាទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២ ("សម្ភារៈ")។ រាល់ឯកសារទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ពន្ធមួយសម្រាប់បំផុតគឺ **ឧបសម្ព័ន្ធ ក**។

2. សហព្រះរាជអាជ្ញាស្វែងរកការអនុញ្ញាតដាក់បង្ហាញសម្ភារៈ ដែលមាននៅក្នុងការដាក់បង្ហាញនេះតាមរយៈសំណើចំនួនបួន (រួមគ្នា ហៅថា "សំណើ") ដែលបានដាក់ទៅសហចៅក្រមស៊ើបអង្កេត (សចស) នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤[1], ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤[2], ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៥[3] និងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥[4]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("សចសអ") បានអនុញ្ញាតឱ្យមានការដាក់បង្ហាញនៃសំណើនេះទាក់ទងទៅនឹងឯកសារ ដែលបច្ចុប្បន្នកំពុងត្រូវបានដាក់បង្ហាញនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦[5] និងនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៦[6] ("សេចក្តីសម្រេច")។ សេចក្តីសម្រេចទាំងនោះត្រូវបានចែកជូនទៅអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃចេញផ្សាយ។

3. សហព្រះរាជអាជ្ញាបានយកចិត្តទុកដាក់អំពីសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២/០២ នៅក្នុង

---

[1] សំណុំរឿង003-**D100** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២, ៥ ឧសភា ២០១៤។

[2] សំណុំរឿង003-**D100/2** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញឯកសារនៃសំណុំរឿង០០៣ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង០០២/០២, ១៥ ធ្នូ ២០១៤។

[3] សំណុំរឿង003-**D100/10** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០៣ ចូលទៅក្នុងសំណុំរឿង០០២, ៣ សីហា ២០១៥។

[4] សំណុំរឿង003-**D100/16** សំណើរបស់ សពអ សុំដាក់បង្ហាញឯកសារនានានៃសំណុំរឿង០០៣ ចូលទៅក្នុងសំណុំរឿង ០០២, ៩ តុលា ២០១៥។

[5] សំណុំរឿង003- **D100/17** សំណើរបស់ សពអ សុំដាក់បង្ហាញឯកសារលេខ D100, D100/2, D100/10, D100/13, D100/14, និង D100/16, ២៨ មករា ២០១៦។

[6] សំណុំរឿង003- **D100/18** សេចក្តីសម្រេចរួមលើសំណើរបស់ សពអ, ២៩ មករា ២០១៦។

សេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥[7]។ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់សហព្រះរាជអាជ្ញា ឲ្យដាក់បង្ហាញដល់អង្គជំនុំជម្រះនេះ និងភាគីនានា នូវភស្តុតាងដោះបន្ទុកពីសំណុំរឿង០០៣ និង០០៤ ដោយឈរលើមូលដ្ឋានជាបន្តបន្ទាប់ រហូតដល់មានការបញ្ចប់សំណុំរឿង០០២/០២[8]។ សេចក្តីសម្រេចនោះក៏បានបង្គាប់ផងដែរដល់សហព្រះរាជអាជ្ញា ឲ្យដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយនៃសំណុំរឿង០០៣ និង០០៤ របស់បុគ្គលទាំងអស់ដែលត្រូវបានស្នើសុំឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២[9]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា សម្ភារៈបន្ថែមណានៅក្នុងសំណុំរឿង០០៣ និង០០៤ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់ ដោយអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានដាក់នៅពេលដែលពាក្យសុំដោយមានសម្អាងហេតុ អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង[10]។

4. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ផងដែរ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីសំណើរបស់ នួន ជា ទាក់ទងទៅនឹងកាតព្វកិច្ចនៃការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង០០២/០១[11]។ ដោយឡែក អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យសហព្រះរាជអាជ្ញា ដាក់បង្ហាញជូនទៅអង្គជំនុំជម្រះតុលាការកំពូល និងភាគីនានា នូវភស្តុតាងនានាដែល៖ (i) បានផ្តល់ដោយសាក្សីដែលបានធ្វើការដោយផ្ទាល់ជាមួយនឹង រស់ ញឹម, ឬ (ii) ទាក់ទងនឹងការប្រឆាំងរបស់ភូមិភាគពាយ័ព្យទៅនឹង ប៉ុល ពត និង នួន ជា នៅមុនថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

5. សហព្រះរាជអាជ្ញាពីមុនបានដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយចំនួនពីរ ដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុងដីកាសម្រេចរបស់ សចសអ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[12]។ ហេតុ

---

[7] **E363/3** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងកាតព្វកិច្ចដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា, ២២ តុលា ២០១៥។

[8] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២១-២៤, ផ្នែកសម្រេចសេចក្តី។

[9] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២៥-២៧, ផ្នែកសម្រេចសេចក្តី។

[10] *ដដែល ដូចខាងលើ*, កថាខណ្ឌ ២៨-៣០, ផ្នែកសម្រេចសេចក្តី។

[11] **F2/4/2** សេចក្តីសម្រេចលើផ្នែកខ្លះនៃសំណើលើកទីបីរបស់ នួន ជា សុំទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែមក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១, ១៦ មីនា ២០១៥, ផ្នែកសម្រេចសេចក្តី។

[12] **E319/41** ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង០០៣ ទៅក្នុងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៣ - D100/17, ១០ មីនា ២០១៦។

ដូច្នេះសហព្រះរាជអាជ្ញាដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយដែលនៅសល់ និងរបាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលទទួលបានការអនុញ្ញាតឲ្យដាក់បង្ហាញតាមដីកាម្រេចរបស់ សចសអ ដែល៖ មានផ្ទុកសម្ភារៈដោះបន្ទុក ជាចម្លើយរបស់បុគ្គលដែលត្រូវបានស្នើសុំឲ្យផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ និង/ឬ ស្ថិតក្នុងប្រភេទនៃភ័ស្តុតាងដែលត្រូវបានបង្គាប់ឲ្យដាក់បង្ហាញដោយអង្គជំនុំជម្រះតុលាការកំពូល[13]។ ក្នុងឧបសម្ពន្ធនានាអមជាមួយ សហព្រះរាជអាជ្ញាបានបង្ហាញនៅក្នុងជួរឈរក្រោមចំណងជើងថា "ប្រភេទនៃការដាក់បង្ហាញ" មូលហេតុសម្រាប់ការដាក់បង្ហាញឯកសារ។ ពាក្យសុំណាមួយអនុលោមតាមវិធាន ៨៧(៤) និងការដាក់បង្ហាញណាមួយនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុញ្ញាតដោយដីកាសម្រេចរបស់ សចសអ នឹងត្រូវដាក់តាមក្រោយក្នុងពេលវេលាសមស្រប។

6. អង្គជំនុំជម្រះសាលាដំបូងបានណែនាំថា ជាដំបូង សហព្រះរាជអាជ្ញាត្រូវដាក់សំណើសុំបង្ហាញរបស់ខ្លួនទៅអង្គជំនុំជម្រះ ដោយប្តឹងពីភ័ស្តុតាងដែលខ្លួនចង់ដាក់បង្ហាញ បន្ទាប់មកទើបដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំឲ្យទទួលយកឯកសារណាមួយ ទុកជាការអនុម័តសម្រាប់ការដាក់បង្ហាញឯកសារ[14]។

7. អង្គជំនុំជម្រះសាលាដំបូង ធ្លាប់បានបង្គាប់ពីមុនថា គ្រប់ការដាក់បង្ហាញឯកសារទាំងអស់ ពីសំណុំរឿង០០៣ និង០០៤ ទៅក្នុងសំណុំរឿង០០២ គប្បីដាក់ និងជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូងជាបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសម្ងាត់បំផុត និងថាបន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការកំណត់ចំពោះឯកសារនោះថាតើ គប្បីដាក់ចំណាត់ថ្នាក់ឡើងវិញថា សម្ងាត់ ឬក៏អត់[15]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង អំពីឯកសារដែលមាននៅក្នុង **ឧបសម្ព័ន្ធ ក** ដោយឈរលើមូលដ្ឋានសម្ងាត់បំផុត។

---

13 *សូមមើល* កថាខណ្ឌ ៤ ខាងលើ។

14 **E127/7/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ព័ត៌មានពាក់ព័ន្ធនឹងចម្លើយសាក្សីសំណុំរឿង០០៣ និងសំណុំរឿង០០៤ ដែលអាចពាក់ព័ន្ធនឹងសំណុំរឿង០០២, ១៦ សីហា ២០១៣, កថាខណ្ឌ២។

15 **E127/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការបង្ហាញអំពីចម្លើយសាក្សីសម្រាប់សាក្សីដែលអាចផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២", ២៤ មករា ឆ្នាំ២០១២, ទំព័រ១។

8. ការផ្តល់សិទ្ធិឲ្យដាក់បង្ហាញសម្ភារៈក្នុង **ឧបសម្ព័ន្ធ ក** គឺត្រូវស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវមួយចំនួនខាងក្រោមដែលកំណត់ដោយ សចសអៈ[16]

ក. សម្ភារៈទាំងអស់ត្រូវចាត់ទុកជាសម្ងាត់។

ខ. ក្នុងករណីដែលសម្ភារៈត្រូវបានទទួលយកធ្វើជាភ័ស្តុតាងនៅក្នុសំណុំរឿង០០២/០២ សម្ភារៈទាំងនោះត្រូវចាត់ទុកជាសម្ងាត់។

គ. សម្ភារៈទាំងនោះមិនត្រូវផ្សព្វផ្សាយឲ្យលើសពីបុគ្គលទាំងឡាយដែលបានកំណត់អត្តសញ្ញាណយ៉ាងជាក់ច្បាស់នៅក្នុងលក្ខខណ្ឌតម្រូវនានាដែលមានចែងនៅក្នុងនោះទេ។

ឃ. ក្នុងករណីដែលមានសាក្សីនានា ដែលឯកសារផ្សេងៗរបស់ពួកគាត់ត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ក** ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ពួកគាត់អាចធ្វើដូច្នេះបាននៅក្នុងវគ្គសវនាការសាធារណៈ ឲ្យតែឈ្មោះ និងព័ត៌មានកំណត់អត្តសញ្ញាណផ្សេងៗរបស់ពួកគាត់ ត្រូវបានរក្សាទុកជាសម្ងាត់ ហើយពួកគាត់ត្រូវបានកំណត់អត្តសញ្ញាណតែដោយរហស្សនាមដែលបានដាក់ សម្រាប់ក្នុងសំណុំរឿង០០២/០២ ប៉ុណ្ណោះ។

ង. សម្ភារៈដែលបានផ្តល់ឲ្យដោយអនុលោមតាម **ឧបសម្ព័ន្ធ ក** មិនត្រូវផ្សព្វផ្សាយដល់សាធារណជនឡើយ ទោះជាក្នុទម្រង់ណាក្តី ឬតាមប្រព័ន្ធព័ត៌មានបែបណាក៏ដោយ ដែលលើសពីភ័ស្តុតាងដែលបានបង្ហាញនៅក្នុងវគ្គសវនាការសាធារណៈនោះឡើយ។

ច. ភាគីណាក៏ដោយ ក្រុមមេធាវីការពារក្តី ឬបុគ្គលដទៃទៀត ដែលត្រូវអាន លើកយោង ឬបើមិនដូច្នោះទេ ប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារនានាដែលបានដាក់បង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ក** ត្រូវកំណត់អត្តសញ្ញាណសាក្សីនានា តែដោយរហស្សនាមដែលបានដាក់សម្រាប់ក្នុងសំណុំរឿង០០២/០២ និងត្រូវប្រើប្រាស់តែការរៀបរាប់ផ្សេងៗ ដែលបានគណនាសមហេតុសមផលប៉ុណ្ណោះ ដើម្បីចៀសវាងនូវការកំណត់អត្តសញ្ញាណសាក្សីរូបនោះ តាមរយៈព័ត៌មានដទៃទៀត។

[16] សេចក្តីសម្រេច, កថាខណ្ឌ៣២។

ឆ. សម្ភារៈទាំងនោះត្រូវផ្តល់ជូនទៅមេធាវីការពារក្តីរបស់ជនជាប់ចោទទាំងពីររូប មេធាវីប្រចាំការរបស់ ខៀវ សំផន (“មេធាវីប្រចាំការ”) និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសំណៅថតចម្លងអេឡិកត្រូនិច។

ជ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់បង្ហាញសម្ភារៈដែលបានផ្តល់ជូនតាមសេចក្តីសម្រេចនេះ ឲ្យទៅតែសមាជិកនៃក្រុមការងាររបស់ពួកគាត់ដែលទទួលបានការងារជាផ្លូវការ តាមវិធាន ២២(៥) និងវិធាន ១២ (៤) *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ជាមួយនឹងកម្មសិក្សាការីដែលត្រូវបានចាត់តាំងជាផ្លូវការប៉ុណ្ណោះ។

ឈ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឲ្យបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងនៃឯកសារដើមដែលពួកគេបានទទួលឡើយ ក្រៅពីសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងនៃឯកសារនោះដោយសមាជិកនៃក្រុមនានារបស់ខ្លួនដែលត្រូវបានណែនាំ ឬត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យមើលសម្ភារៈសម្ងាត់នោះប៉ុណ្ណោះ។

ញ. មេធាវីការពារក្តី មេធាវីប្រចាំការ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវរក្សាកំណត់ហេតុស្តីពីសំណៅដែលខ្លួនបោះពុម្ព ផលិតឡើងវិញ ថតចម្លង ស្កេន ឬក៏ចម្លងនូវសំណៅថតចម្លងសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ក្នុងរបៀបមួយដែលអាចត្រួតពិនិត្យឡើងវិញបាន។

ដ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីសំណៅគ្មានការអនុញ្ញាតណាមួយនៃសម្ភារៈដែលបានផ្តល់ជូនតាមរយៈដីកាសម្រេចនេះ សមាជិករូបនោះត្រូវចាត់គ្រប់វិធានការទាំងអស់ជាបន្ទាន់ ដើម្បីរក្សាការពារសុវត្ថិភាព និងប្រគល់សំណៅសម្ភារៈឯកសារនោះជូន សចស វិញ។ និង

ឋ. ប្រសិនបើសមាជិកណាម្នាក់នៃភាគីនានា ឬអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង ០០២/០២ ដឹងអំពីការរំលោភបំពានលក្ខខណ្ឌ និងការដាក់កម្រិតទាំងនេះ សមាជិករូបនោះត្រូវរាយការណ៍អំពីការរំលោភបំពាននោះជូន សចស។

## II. ដំណោះស្រាយដែលស្នើឡើង

9. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយក និង ទទួលដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២ នូវឯកសារដូចបានកំណត់អត្តសញ្ញាណក្នុង **ឧបសម្ព័ន្ធក**៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |